នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 29-Sep-2014, 15:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្ដីពីបណ្ដឹងសាទុក្ខ
ចំពោះសេចក្ដីសម្រេច នៅក្នុងសំណុំរឿង០០២/០១**

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**
សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

## I. សេចក្តីផ្តើម

១- អនុលោមតាមវិធាន១០៥(៣)[1] នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាដាក់នូវសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខនេះ (“សេចក្តីជូនដំណឹង”) ជូនអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ទាក់ទងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១(“សាលក្រម”)[2]។

២- សហព្រះរាជអាជ្ញាដាក់បណ្តឹងសាទុក្ខនេះ ដើម្បីជាផលប្រយោជន៍ដល់ច្បាប់ (*dans l’intérêt de la loi*) ក្នុងហេតុផលតែមួយគត់ ដែលថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធមិនធ្វើការពិចារណាលើទម្រង់ទីបី (ឬ “ទម្រង់ពង្រីកបន្ថែម extended form”) នៃទម្រង់ការទទួលខុសត្រូវនៅក្នុងសហឧក្រិដ្ឋកម្មរួម(“JCE III”)គឺជាបញ្ហាផ្លូវច្បាប់ចំពោះសារៈសំខាន់ជាទូទៅមួយនៃច្បាប់យុត្តិសាស្ត្ររបស់ អវតក ដែលធានាចំពោះការធ្វើសវនាការលើបណ្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញាមិនរិះរកឲ្យមានការផ្លាស់ប្តូរនៅផ្នែកបញ្ញត្តិណាមួយនៃសាលក្រមនេះទេ។

៣- សហព្រះរាជអាជ្ញានឹងសន្និដ្ឋានថា (១) បណ្តឹងសាទុក្ខនេះអាចទទួលយកបាន និង (២) អង្គជំនុំជម្រះគួរតែ **ប្រកាស** អំពីភាពមានស្រាប់នៃ JCE III ដែលជាទម្រង់នៃការទទួលខុសត្រូវ ក្នុងអម្លុងពេលនៃយុត្តាធិការពេលវេលារបស់ អវតក។

៤- វិធាន១០៧(៤) នៃវិធានផ្ទៃក្នុងបានចែងថា សេចក្តីជូនដំណឹងលើបណ្តឹងសាទុក្ខពីភាគីណាមួយត្រូវតែដាក់នៅក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម *ឬ* ពីថ្ងៃជូនដំណឹង។ មាត្រា៨.២ នៃសេចក្តីណែនាំអនុវត្តជាធរមាន[3] បានចែងថា៖ “អង្គជំនុំជម្រះអាចកំណត់កាលបរិច្ឆេទសម្រាប់ដាក់សំណើ ឬបណ្តឹង”។ កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានអនុញ្ញាតជាផ្នែកនៅក្នុងសំណើសុំរួមរបស់មេធាវីការពារក្តី ដែលសុំបន្ថែមពេលវេលាកំណត់សម្រាប់ដាក់សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ និងបានបង្គាប់ថា “*រាល់សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខទាំងអស់* ត្រូវតែដាក់នៅក្នុងអម្លុងពេលមិនឲ្យលើសពី៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹង

---

[1] អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធ. លើកទី៨), ដែលបានពិនិត្យឡើងវិញកាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ ២០១១ (“វិធានផ្ទៃក្នុង”)។

[2] ឯកសារលេខ **E313** សាលក្រមសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ (“សាលក្រម”)។

[3] សេចក្តីណែនាំអនុវត្ត អវតក /២០០៧/១/វិសោធ.ទី៨, ស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក, ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២។

នៃសេចក្តីសម្រេចនេះ”[4] នេះមានន័យថា មិនឲ្យហួសពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ (“ សេចក្តីសម្រេចស្តីពីពេលវេលាកំណត់”)។ សហព្រះរាជអាជ្ញាលើកជាយោបល់ថា សេចក្តីជូនដំណឹងនេះគឺស្របតាមមាត្រា៨.២ និងត្រូវដាក់ជូននៅក្នុងពេលយ៉ាងយូរ៣០ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹងនេះ គឺទាន់ពេលវេលាហើយ។

## II. សេចក្តីជូនដំណឹងអំពីជំហរនៅក្នុងការទទួលយក

៥- វិធានស្តីពីនីតិវិធីដែលបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ បានបញ្ជាក់ថាដំណោះស្រាយតាមផ្លូវច្បាប់គឺមានស្រាប់តាមរយៈតុលាការឧទ្ធរណ៍នានា ដោយផ្អែកលើមូលដ្ឋានច្បាប់នៃ “សារៈសំខាន់ជាទូទៅ” ឬ “សារៈសំខាន់ច្រើន” ដល់ច្បាប់យុត្តិសាស្ត្រ[5]។ អង្គជំនុំជម្រះនេះបានប្រកាន់យកយ៉ាងច្បាស់តាមបទដ្ឋានផ្លូវច្បាប់ដូចគ្នា ក្នុងសាលក្រមបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿងលេខ ០០១[6]។ ជំហរនេះក៏ត្រូវបានបង្កើតឡើងយ៉ាងល្អដែរនៅក្នុងច្បាប់របស់ប្រទេសបារាំង តាមរយៈដំណោះស្រាយតាមផ្លូវច្បាប់វិសាមញ្ញដែលហៅថា *pourvoi en cassation dans l’intérêt de la loi*[7]។

## III. ការជូនដំណឹងអំពីបញ្ហាដែលបានលើកឡើង

៦- នៅកថាខណ្ឌ ៦៩១ នៃសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះមិនចាត់ទុកសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ថាជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់សហជនជាប់ចោទឡើយ ដោយបានយោងទៅសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០១១ ដែលបានសម្រេចថា “សហឧក្រិដ្ឋកម្ម

---

[4] ឯកសារលេខ **F3/3** សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី ដែលសុំបន្ថែមពេលវេលា និងចំនួនទំព័រ ពីលើចំនួនកំណត់ នៅក្នុងសេចក្តីជូនដំណឹងបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខ, ចុះថ្ងៃទី២៩ ខែសីហា ២០១៤ ត្រង់ទំព័រ១១ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។

[5] សូមមេត្តាអាន, *ក្នុងចំណោមសាលដីកាបណ្តឹងសាទុក្ខនានាជាច្រើន*, នូវសាលដីកាបណ្តឹងសាទុក្ខក្នុងករណីរឿងរបស់ *Stakić* ត្រង់កថាខណ្ឌទី៧។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងករណីរឿងរបស់ *Kupreškić និងគូរកន,* ត្រង់កថាខណ្ឌទី២២។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងករណីរឿងរបស់ *Tadić,* ត្រង់កថាខណ្ឌទី២៤៧។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងករណីរឿងរបស់*Akayesu,* ត្រង់កថាខណ្ឌទី១៨។

[6] ឯកសារលេខ **F28** សាលក្រមលើបណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌទី១៥។

[7] ក្រមនីតិវិធីព្រហ្មទណ្ឌ(បារាំង), មាត្រា៦២០ -៦២១។

រួមទម្រង់ទី III មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬនៅក្នុងច្បាប់កម្ពុជានោះទេ ត្រឹមឆ្នាំ១៩៧៥”[8]។

៧- សហព្រះរាជអាជ្ញានឹងលើកឡើងនូវសំណួរផ្នែកអង្គច្បាប់ខាងក្រោម ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការសម្រេច។

*តើទម្រង់ទី III (ឬទម្រង់ទូលាយ) នៃទម្រង់នៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ដែលអាចអនុវត្តបាននៅ អ.វ.ត.ក ជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ នៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក គ្រាន់តែត្រូវបំពេញលក្ខខណ្ឌតម្រូវធម្មតានៃការជូនដំណឹងទៅជនជាប់ចោទតែប៉ុណ្ណោះ?*

៨- អង្គជំនុំជម្រះត្រូវផ្តល់នូវការណែនាំផ្លូវច្បាប់ច្បាស់លាស់ ដោយសារតែមូលហេតុយ៉ាងហោចណាស់ចំនួន ៤ ដែលមានការពាក់ព័ន្ធគ្នា ដែលសហព្រះរាជអាជ្ញានឹងបង្ហាញមូលហេតុទាំង ៤ នេះនៅក្នុងសារណាបណ្តឹងសាទុក្ខ។

1) ទីមួយ ការអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី III ត្រូវបានអង្គបុរេជំនុំជម្រះ[9] និងអង្គជំនុំជម្រះសាលាដំបូង[10] ពិចារណា ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនទាន់បានដោះស្រាយបញ្ហានេះឲ្យបានច្បាស់លាស់ទាំងនៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២ នៅឡើយទេ។

2) ទីពីរ សហជនជាប់ចោទត្រូវបានជូនដំណឹង ព្រោះថានៅក្នុងសវនាការបឋមបន្ថែមកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាលើកឡើងថា ខ្លួននឹងស្នើឲ្យអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី III សម្រាប់បទចោទផ្សេងៗដែលកំពុងត្រូវបានពិនិត្យនៅក្នុងសំណុំរឿង០០២/០២[11] ដែលសហព្រះរាជអាជ្ញាយល់ថាជាការត្រឹមត្រូវផ្នែកអង្គហេតុដែលត្រូវកំណត់ឲ្យមានការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មទម្រង់ទី III ដែលនេះជាការកំណត់ប្រភេទបទល្មើស *ម្យ៉ាងទៀត* ចំពោះការប្រព្រឹត្តិរបស់សហជនជាប់ចោទ[12]។

---

[8] ឯកសារ **E313** សាលក្រមខាងលើ ចំណុចទី២ ត្រង់កថាខណ្ឌ៦៩១។ ដកស្រង់ ឯកសារ **E100/6** សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១។

[9] [ដកស្រង់]

[10] [ដកស្រង់]

[11] [ដកស្រង់]

[12] ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ម៉ោង 10:12:15។

3) ទីបី អង្គជំនុំជម្រះតុលាការកំពូលនៃ ICTR បានលើកឡើងយ៉ាងច្បាស់ថា "...អាចថាមិនមានការចោទជាសំណួរទៅលើថាតើ សហឧក្រិដ្ឋកម្មទម្រង់ទី III ត្រូវបានទទួលស្គាល់យ៉ាងច្បាស់លាស់នៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិនោះទេ"[13]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលនេះបានចាត់ទុកយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ថា "មិនចងកាតព្វកិច្ច" ហើយត្រូវ "ពិនិត្យដោយប្រយ័ត្នប្រយែង និងមានហេតុផល"[14] សហព្រះរាជអាជ្ញាមិនឃើញមានភស្តុតាងណាមួយអំពីការវិវត្តផ្សេងៗនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៩២ ដែលបង្ហាញពីការកែប្រែណាមួយចំពោះស្ថានភាពនៃច្បាប់អន្តរជាតិទាក់ទងនឹងសហឧក្រិដ្ឋកម្មទម្រង់ទី III ទោះក្នុងទម្រង់ជាការប្រព្រឹត្តិរួមគ្នា ឬជាការទទួលខុសត្រូវដោយសារតែការចូលរួមដោយប្រយោល។ បើសិនជាការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា សហឧក្រិដ្ឋកម្មទម្រង់ទី III មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទំលាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានតម្កល់ និងអនុវត្ត នោះបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៃ ICTY មានកំហុសនៅក្នុងការផ្តន្ទាទោសដោយផ្អែកទៅលើសហឧក្រិដ្ឋកម្មទម្រង់ទី III ចំពោះការប្រព្រឹត្តិពីឆ្នាំ១៩៩២ មកនោះ ហើយដូច្នេះ ការផ្តន្ទាទោសមួយចំនួន *ក្នុងនោះរួមទាំង* ក្នុងសំណុំរឿង *Tadić*[15] *Krstić*[16] និង *Stakić*[17] មិនអាចការពារបានជោគជ័យនោះទេ។ ការសម្រេចបែបនេះក៏អាចធ្វើឱ្យការសម្រេចលើអង្គច្បាប់ស្ថាពររបស់អង្គជំនុំជម្រះ

---

[13] ដូចខាងលើ កថាខណ្ឌ១៣។

[14] សំណុំរឿង០០១ ឯកសារ **F28** សាលដីកា ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ៩៧។

[15] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Tadić* កថាខណ្ឌ ២៣២ ["ដើមបណ្តឹងឧទ្ធរណ៍បានជ្រាបថា ទង្វើនានារបស់ក្រុមដែលខ្លួនគាត់ជាសមាជិកមួយដែរនោះ ទំនងជានឹងនាំដល់ការសម្លាប់បែបហ្នឹងហើយ ប៉ុន្តែគាត់មានឆន្ទៈជ្រើសរើសយកការប្រថុយនោះ"] ។ សូមមើលផងដែរ កថាខណ្ឌ ២៣៣-២៣៤។

[16] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Krstić* កថាខណ្ឌ១៥១ ["ការទទួលខុសត្រូវរបស់ Radislav Krstić ទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅ Potočari គឺកើតចេញពីការចូលរួមជាបុគ្គលរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម ក្នុងការជម្លៀសជនស៊ីវិលដោយបង្ខំ។ ឧក្រិដ្ឋកម្មកាលានុវត្តនិយមទាំងនោះគឺជាផលវិបាកតាមសភាពធម្មជាតិ និងដែលប្រមើលទុកជាមុនបាននៃសហឧក្រិដ្ឋកម្មរួមនោះ"]។

[17] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Stakić* កថាខណ្ឌ ៨៦-៩៨ ។ កថាខណ្ឌ៩៨ ["...អង្គជំនុំជម្រះសាលាឧទ្ធរណ៍សន្និដ្ឋានថាសម្អាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបង្ហាញបញ្ជាក់ថាដើមបណ្តឹងឧទ្ធរណ៍មានធាតុផ្សំអត្តនោម័តដែលត្រូវទទួលខុសត្រូវក្រោមទម្រង់ទី III នៃសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋមនុស្សឃាត (ជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ") និងការសម្លាប់រង្គាល"]។

តុលាការកំពូលនៃ ICTR នៅក្នុងរឿងក្តី *Karemera និងអ្នកផ្សេងទៀត*[18] និងអង្គជំនុំជម្រះតុលាការកំពូលនៃ SCSL នៅក្នុងរឿងក្តី *Brima និងអ្នកផ្សេងទៀត*[19]។

4) ទីបួន នៅពេលបច្ចុប្បន្ននេះ ការសម្រេចរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្តីពីទម្រង់សហឧក្រិដ្ឋកម្មទម្រង់ទី III មានភាពខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការដែលមានលក្ខណៈជាអន្តរជាតិដែលជាដៃគូផ្សេងទៀត។ ស្ថានភាពបច្ចុប្បន្ននៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក មានភាពផ្ទុយគ្នាទាំងស្រុងជាមួយនឹងអង្គជំនុំជម្រះតុលាការកំពូលនៃ STL ដែលបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចមួយក្នុងឆ្នាំ២០១១ ថា សហឧក្រិដ្ឋកម្មទម្រង់ទី III ពិតជាត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់អន្តរជាតិបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ហើយសហឧក្រិដ្ឋកម្មទម្រង់ទី III នេះត្រូវបានផ្តល់យុត្តិកម្មពេញលេញដោយគោលនយោបាយសាធារណៈអន្តរជាតិ មិនរំលោភដល់គោលការណ៍នៃការទទួលខុសត្រូវ (*nullum crimen sine culpa*) ហើយមិនមានភាពអយុត្តិធម៌ចំពោះពិរុទ្ធជនឡើយ ព្រោះថាភាពខុសគ្នារវាងកម្រិតនៃពិរុទ្ធភាពចំពោះជនល្មើសកម្រិតទីមួយ និងកម្រិតទីពីរ ជាការសមស្របដោយមិនលើកលែងការទទួលខុសត្រូវរបស់ជនល្មើសកម្រិតទីមួយទេ ប៉ុន្តែ តាមរយៈការថ្លឹងថ្លែងកំណត់ឲ្យបានត្រឹមត្រូវចំពោះការកំណត់ទោស[20]។

---

[18] រឿងក្តី *Karemera និងអ្នកផ្សេងទៀត* សាលក្រម កថាខណ្ឌ ១៤៨២ ["...អង្គជំនុំជម្រះលំបាកជឿថា [Ngirumpatse] មិនត្រូវបានជូនដំណឹង ដូច្នេះហើយមិនបានដឹងថាមានការរំលោភ និងការបំពានផ្លូវភេទទៅលើស្ត្រី និងក្មេងស្រី Tutsi នៅគ្រប់កន្លែងក្នុងប្រទេស Rwanda។ ដោយសារតែការរំលោភ និងការបំពានផ្លូវភេទទៅលើស្ត្រី និងក្មេងស្រី Tutsi កើតមានច្រើន ហើយត្រូវបានប្រព្រឹត្តក្នុងលក្ខណៈចំហ និងយ៉ាងអាក្រក់ក្នុងរយៈពេលយូរ ...]។ រឿងក្តី *Karemera និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ២០០ )ច្រានចោលការផ្តន្ទាទោសដោយផ្អែកទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ដោយសារតែអត់មានសម្អាងហេតុផ្អែកអង្គហេតុជាក់លាក់នៅពេលជំនុំជម្រះ ប៉ុន្តែតម្កល់ច្បាប់ជាធរមាន។

[19] រឿងក្តី *Brima និងអ្នកផ្សេងទៀត* សាលដីកា កថាខណ្ឌ ៨៧ ["អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់នៅពេលដែលអង្គជំនុំជម្រះសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមមិនត្រូវបានបង្ហាញឲ្យបានត្រឹមត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដូច្នេះ មូលដ្ឋានទីបួនរបស់រដ្ឋអាជ្ញាទទួលបានការគាំទ្រ យ៉ាងណាក៏ដោយយើងមើលឃើញថាមិនចាំបាច់ផ្តល់សម្អាងហេតុលើអង្គហេតុបន្ថែមទៀត ឬបញ្ជូនសំណុំរឿងទៅអង្គជំនុំជម្រះសាលាដំបូងវិញក្នុងគោលបំណងនេះឡើយ ដោយគិតគូរពីផលប្រយោជន៍នៃយុត្តិធម៌"]។

[20] តុលាការ STL11-01/I សេចក្តីសម្រេចបន្ទាន់បង្គំទៅលើច្បាប់ជាធរមាន៖ ភេរវកម្ម ការឃុំគំនិត មនុស្សឃាត ការប្រព្រឹត្តិបទល្មើស ការចោទប្រកាន់រួម )អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២៤៥។

៩- ការអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលគឺជាការចាំបាច់ ដើម្បីផ្តល់ជាការណែនាំផ្លូវច្បាប់ចំពោះអង្គជំនុំជម្រះសាលាដំបូង ជាពិសេសដោយសារតែវិសាលភាពមានកម្រិតកំណត់នៃបណ្តឹងសាទុក្ខបន្ទាន់បង្ខំនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៃ អ.វ.ត.ក ព្រោះថាបើសិនជាគ្មានការណែនាំនេះទេ អង្គជំនុំជម្រះសាលាដំបូងមិនអាចអនុវត្តសហឧក្រិដ្ឋកម្មទម្រង់ទី III ដោយសារតែគ្មានលទ្ធភាពជាក់ស្តែងនៃលក្ខខណ្ឌតម្រូវនៃការជូនដំណឹងសមស្រប ចំពោះជនជាប់ចោទ។ ភាពសុខដុម និងសង្គតិភាពនៃយុត្តិសាស្ត្រក៏ជាគោលបំណងដ៏សំខាន់នៃគោលនយោបាយផ្នែកច្បាប់អន្តរជាតិនៃប្រព័ន្ធដែលមិនទាន់មានលក្ខណៈពេញលេញនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិដែលព្យាយាមសម្រេចគុណតម្លៃនៃ (ក) លទ្ធភាពដូចគ្នាចំពោះការការពារដោយច្បាប់នៅក្នុងចំណោមយុត្តាធិការអន្តរជាតិ (ខ) សច្ចភាពគតិយុត្តិចំពោះជនត្រូវចោទ និងជនជាប់ចោទនៃបទល្មើសព្រហ្មទណ្ឌអន្តរជាតិ (គ) ការព្រមាននិងប្រាកដក្នុងការប្រព្រឹត្តិបទល្មើសបែបនេះតាមរយៈការអនុវត្តច្បាប់ដូចគ្នា និង (ឃ) ការផ្តល់ប្រភពសម្រាប់អនុវត្តដ៏ប្រសើរនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិ[21] ដែលជាគោលបំណងច្បាស់លាស់របស់ អ.វ.ត.ក ក្នុងការបន្សល់ទុកនូវកេរ្តិ៍ដំណែល។ សហព្រះរាជអាជ្ញាស្នើថា កត្តាបន្ថែមទាំងនេះគាំទ្របន្ថែមទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យមានការអន្តរាគមន៍ និងការណែនាំផ្លូវច្បាប់ដោយយុត្តាធិការកំពូលនៃ អ.វ.ត.ក។

១០- ដើម្បីធ្វើឱ្យមានភាពច្បាស់លាស់ថែមទៀត សហព្រះរាជអាជ្ញាបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចលើផ្នែកបញ្ញត្តិនៃសាលក្រម ឬលើការរកឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ នៅក្នុងសាលក្រមនោះឡើយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>**សហព្រះរាជអាជ្ញា** | | [signature] |

[21] សូមមើល ពាក់ព័ន្ធនឹងចំណុច (ឃ) តែប៉ុណ្ណោះ 'យោបល់' របស់ B Swart នៅក្នុងរឿងក្តី A Klip and G Sluiter (eds) *ករណីសំខាន់ៗរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដែលត្រូវបានធ្វើចំណារ ភាគ II៖ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ឆ្នាំ ១៩៩៤-១៩៩៩* (Antwerp: Intersentia, 2001) នៅចំណុច ២០១។ រឿងក្តី G Sluiter, H Friman, S Linton និងអ្នកផ្សេងទៀត *នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ៖ គោលការណ៍ និងវិធាន* (Oxford: OUP, 2013) នៅចំណុច ៣៧៧។